ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ៥៤
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ ៣៣
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ២៣០
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២
**សាលក្រមព្រហ្មទណ្ឌ**
**លេខ ១២ "ឲ"/៣២៤**
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២

# សាលក្រម
# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការលេខ ក (១) នៃសាលាដំបូងខេត្តសៀមរាប ។

-កាលបរិច្ឆេទបើកសវនាការ ៖ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ វេលាព្រឹក ។

-កាលបរិច្ឆេទប្រកាសសាលក្រម ៖ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ វេលាព្រឹក ។

## ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ឋានៈប្រធានក្រុមប្រឹក្សា
លោកស្រី ឋានៈចៅក្រមប្រឹក្សា
លោក ឋានៈចៅក្រមប្រឹក្សា

លោកស្រី ឋានៈព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជី

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៥៤ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុថាត់ ភេទប្រុស អាយុ ២០ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២) ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅភូមិសំបួរ ឃុំសំបួរ ស្រុកក្រឡាញ់ ខេត្តសៀមរាប មុខរបរ លក់ដូរ កម្រិតវប្បធម៌ថ្នាក់ទី០៩ ឪពុកឈ្មោះ [redacted] ធឿម "រស់" ម្តាយឈ្មោះ [redacted] ភាព "រស់" នៅលើប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន ។ (ក្នុងឃុំ)

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥ យឧ/៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ។

-លោកស្រី ប៊ុល ស្រីនាថ ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទៈ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " ប្រព្រឹត្តនៅភូមិពេជ្ជោរ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អង្គហេតុនៃរឿងមានដូចតទៅៈ

កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទី នៅចំណុចភូមិពេជ្ជោរ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកក្រឡាញ់បានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ នឿន សុថាត់ ភេទប្រុស អាយុ ២០ឆ្នាំ និងធ្វើការដកហូតវត្ថុតាងបានគ្រឿងញៀន ពណ៌ស លាយWY ពណ៌ក្រហម ចំនួន ០១ កញ្ចប់ មានទម្ងន់សុទ្ធ ២៥,៨៧ ក្រាម ហើយសមត្ថកិច្ចបានធ្វើការសួរនាំជនជាប់ចោទខាងលើបានឆ្លើយសារភាពថា រូបគេធ្លាប់ទិញគ្រឿងញៀន ពីបុរសមិនស្គាល់ឈ្មោះចំនួនបីលើកមកហើយ ដោយក្នុងមួយលើកៗទិញចំនួន ៤០០.០០០ (សែសិបម៉ឺន) រៀល ទៅ



Scanned with CamScanner

៥០០.០០០ (ហាសិបម៉ឺន) រៀល យកទៅវែកជាកញ្ចប់តូចៗ ដើម្បីលក់បន្តដោយបានតម្លៃចាប់ពី ៤០.០០០ (បួនម៉ឺន) រៀល ឡើងទៅ ។

បានឃើញ របាយការណ៍សរុបលេខ ០០៧/២០២២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៩១ អយច/២២ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦១៧ ពស.ព្រស/៣ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ ៣២០ ពស.ព្រជ (ក) ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុថាត់ បានឆ្លើយថា: ខ្លួនទៅបន្ទាយមានជ័យវេលាម៉ោង ១២ យប់ នៅថ្ងៃទី១១ខែមករា ឆ្នាំ២០២២ ដើម្បីទៅលក់ស្រាក្រឡុក ដោយស៊ីឈ្នួលគេទេ ។ ខ្លួនជិះម៉ូតូពីនាក់ប្អូនឈ្មោះ ត្រា ស្រាប់តែមានគេជិះម៉ូតូពីនាក់ដេញខ្លួនពីក្រោយហៅឱ្យឈប់ ដោយស្មាត់ខ្លួនមិនហ៊ានឈប់ទេ ព្រោះពួកគេមានដំបង ហើយពួកគេវាយប្អូនខ្លួនមួយដំបងចំខ្នង ភ្លាមនោះប្អូនខ្លួនក៏រត់បាត់ ហើយពួកគេហៅសមត្ថកិច្ចប្អូនប្រាំនាក់មកចាប់ខ្លួនទៅប៉ុស្តិ៍ចំនួនមួយយប់ ។ ព្រឹកឡើងមានលេខទូរស័ព្ទខាងក្រុមហ៊ុន វីរៈប៊ុនថាំ ហៅឱ្យទៅយកអ៊ីវ៉ាន់ ។ ក្រោយមកសមត្ថកិច្ចដកហូតទូរស័ព្ទពីខ្លួនមួយសន្ទុះក្រោយមកសមត្ថកិច្ចយកថ្នាំញៀនមួយកញ្ចប់បើកមុខខ្លួនថា ជារបស់ខ្លួន ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាំងពីឆ្នាំ២០១៨ ហូតដល់បច្ចុប្បន្ន ដោយថ្នាំញៀនទិញពីប៉ោយប៉ែត ។ ខ្លួនសុំបដិសេធចម្លើយនៅសមត្ថកិច្ច ដោយសារសមត្ថកិច្ចវាយខ្លួនឱ្យទទួលយកចម្លើយទាំងនេះ ។ នៅពេលមកដល់តុលាការខ្លួនបានឆ្លើយបដិសេធចម្លើយនៅសមត្ថកិច្ចនេះដែល ។ ទូរស័ព្ទដែលគេខលមកខ្លួន មិនមែនជាទូរស័ព្ទខ្លួនទេ ហើយក៏មិនដឹងថាទូរស័ព្ទរបស់អ្នកណាដែរ ហើយលេខ ០៩៦ ៧៥ ៧៣ ១៦៦ ជាលេខរបស់ខ្លួន ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ជនជាប់ចោទបដិសេធថា គាត់មិនបានលក់ថ្នាំញៀន ហើយថ្នាំញៀនដកហូត មិនមែនជារបស់ខ្លួនទេ ។ ចម្លើយនេះគ្មានភស្តុតាងបញ្ជាក់ បើតាមចម្លើយនៅសមត្ថកិច្ចជនជាប់ចោទថា បានទិញថ្នាំញៀនពី ៥០០.០០០ (ហាសិប) ម៉ឺនរៀល និង ៤០០.០០០ (សែសិប) ម៉ឺនរៀល យកវែកលក់បន្តពីមួយកញ្ចប់ ក្នុងតម្លៃ ៤០.០០០ (បួនម៉ឺន) រៀល ។ ជនជាប់ចោទថា សមត្ថកិច្ចវាយ តំណាងអយ្យការពុំជឿទេ ព្រោះគ្មានអ្វីបញ្ជាក់ឡើយ ។ ថ្នាំញៀនដែលដកហូតពី ជនជាប់ចោទមានទម្ងន់សុទ្ធ = ១៩ ក្រាម លើសពី ១៥ ក្រាម ដែលជាបទល្មើសឧក្រិដ្ឋ ។ ដូចនេះ តំណាងអយ្យការ នៅតែរក្សាបទចោទប្រកាន់លើជនជាប់ចោទ តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទសារភាពថាខ្លួនចេះតែប្រើប្រាស់ថ្នាំញៀនប៉ុណ្ណោះ ហើយខ្លួនមិនចេះជួញដូរថ្នាំញៀនទេ ។ ពេលមកដល់សមត្ថកិច្ចឃាត់នោះមិនបានដកយកថ្នាំញៀននោះទេ ។ លុះដល់ម៉ោង ១០ ព្រឹក សមត្ថកិច្ចបានហុចទូរស័ព្ទឱ្យកូនក្តីខ្លួនឱ្យនិយាយ ក្រោយមកក៏មាន

ថ្នាំញៀនយកមកបង្ហាញកូនក្ដីខ្លួនតែម្ដង ។ សំណូមពរៈ ស្នើសុំឱ្យតុលាការប្ដូរបទចោទ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ទៅបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនវិញ ពីព្រោះកូនក្ដីខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] សុថាត់ បានសំណូមពរមកតុលាការថាៈ ស្នើសុំឱ្យតុលាការប្ដូរបទចោទ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ទៅបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនវិញ ដោយសារខ្លួន ធ្លាប់តែប្រើប្រាស់ថ្នាំញៀនប៉ុណ្ណោះ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្ដុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.តាមរបាយការណ៍សរុបលេខ ០០៧/២២ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន ថាៈ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ០២ និង ០០ នាទី កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុកក្រឡាញ់ បានបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅចំណុចភូមិក្រឡាញ់ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប ឃាត់ខ្លួនឈ្មោះ [redacted] សុថាត់ ដកហូតថ្នាំញៀនចំនួន ០១ កញ្ចប់ ទម្ងន់ ២៥,៨៧ ក្រាម នៅក្នុងថង់ពណ៌ស្លាទំ ក្នុងកំប៉ុងឡេ ពណ៌ខ្មៅ នៅក្នុងល្បាយម្សៅពណ៌ស ។ ក្រោយឃាត់ខ្លួនឈ្មោះ [redacted] សុថាត់ បានឆ្លើយសារភាពថា ថ្នាំញៀននេះគេទិញពី បុរសមិនស្គាល់ឈ្មោះតាមទូរស័ព្ទ Private ចំនួនបីដង ទិញលើកទីមួយតម្លៃ ៥០០.០០០ (ហាសិបម៉ឺន) រៀល លើកទីពីរ និងលើកទីបីតម្លៃ ៤០០.០០០ (សែនសិបម៉ឺន) រៀល យកមកវែកកញ្ចប់តូចៗលក់បន្តចាប់ពីតម្លៃ ៤០.០០០ (បួនម៉ឺន) រៀល ឡើងទៅ ។

២.ជនជាប់ចោទឈ្មោះ [redacted] សុថាត់ បានឆ្លើយដោះសារថាៈ ខ្លួនមិនដែលធ្លាប់ទិញថ្នាំញៀនពីបុរសមិនស្គាល់ឈ្មោះ ចំនួន ៥០០.០០០ (ហាសិបម៉ឺន) រៀល និង ៤០០.០០០ (សែសិបម៉ឺន) រៀល ដើម្បីយកទៅវែកជាកញ្ចប់តូចៗទេ ហើយក៏មិនបានលក់ថ្នាំញៀនបន្តក្នុងតម្លៃចាប់ពី ៤០.០០០ (បួនម៉ឺន) រៀល ឡើងទៅ នោះដែរ ។ តាមចម្លើយដោះសាររបស់ជនជាប់ចោទឈ្មោះ [redacted] សុថាត់ ថាៈ មិនបានទិញថ្នាំញៀនពីបុរសមិនស្គាល់ឈ្មោះ តាមទូរស័ព្ទលេខ Private និងមិនធ្លាប់វែកថ្នាំញៀនជាកញ្ចប់តូចៗដែរ ។ ចម្លើយដោះសាររបស់ជនជាប់ចោទនេះ ពុំមានភស្ដុតាងបញ្ជាក់អាចឱ្យតុលាការជឿបានឡើយ បើផ្អែកតាមការឃាត់ខ្លួនជនជាប់ចោទក្នុងបទល្មើសជាក់ស្ដែងដកហូតថ្នាំញៀនពីជនជាប់ចោទ និងសមត្ថកិច្ចធ្វើការស្រាវជ្រាវជនជាប់ពាក់ព័ន្ធនឹងជនសង្ស័យជិះម៉ូតូគេចខ្លួនពីសមត្ថកិច្ច ។ ដូចនេះ ផ្អែកតាមអង្គហេតុ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ អាចឱ្យតុលាការសន្និដ្ឋានថា កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ឈ្មោះ [redacted] សុថាត់ បានទូរស័ព្ទទៅលេខ Private ដើម្បីទិញថ្នាំញៀន ។ បន្ទាប់មកឈ្មោះ [redacted] សុថាត់ បានយកថ្នាំញៀន នោះមកវែកជាកញ្ចប់តូចៗ ដើម្បីយកទៅលក់ចាប់ពីតម្លៃ ៤០.០០០ ម៉ឺនរៀល ឡើងទៅ ។ ក្រោយមកសមត្ថកិច្ចសង្ស័យនៅឃើញឈ្មោះ [redacted] សុថាត់ និងឈ្មោះ ត្រា (គេចខ្លួន) ក៏ធ្វើការឃាត់ខ្លួនតែម្ដង ។



Scanned with CamScanner

៣.តាមចម្លើយជនជាប់ចោទខាងលើ និងភស្តុតាងឯកសារពាក់ព័ន្ធនឹងសំណុំរឿង ឃើញថា: ពុំមានចម្លើយ ឬ ឯកសារបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុថាត់ ទិញថ្នាំញៀនយកមកប្រើប្រាស់ខ្លួនឯងនោះទេ ។ ដូចនេះ អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សុថាត់ គឺជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.តាមកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យបទល្មើសគ្រឿងញៀន គឺឈ្មោះ [redacted] សុថាត់ សមត្ថកិច្ចពិនិត្យភិនភាគវត្ថុតាងមាន៖ (១).ម្សៅគ្រីមពណ៌ស លាយWY ចំនួន ០១ កញ្ចប់ ទម្ងន់ ២៥,៨៧ ក្រាម នៅក្នុងថង់ពណ៌ស្លាទំ ក្នុងកំប៉ុងឡេ ពណ៌ខ្មៅ នៅក្នុងល្បាយម្សៅពណ៌ស (២).ទូរស័ព្ទដៃម៉ាក VIVO ពណ៌ស ចំនួន ០១ គ្រឿង (៣).ម៉ូតូម៉ាក HONDA DREAM ស៊េរីឆ្នាំ២០២១ លេខតួលេខម៉ាស៊ីន ND១២៥ MDM-៥៩៧៦៧៥៤ គ្មានស្លាកលេខ ចំនួន ០១ គ្រឿង ។

៥.តាមកំណត់ហេតុស្តីពីតេស្តស្វែងរកសារធាតុញៀន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២២១ របស់ការិយាល័យបទល្មើសគ្រឿងញៀន គឺបានធ្វើតេស្តទឹកនោមលើឈ្មោះ [redacted] សុថាត់ ជាលទ្ធផល វិជ្ជមាន (តម្រុយមេតំហ្វេតាមីន) ។

៦.តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៥៥៤៤/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានធ្វើកោសលវិច័យម្សៅក្រាម ពណ៌សថ្លារបស់ឈ្មោះ នឿន សុថាត់ ដោយសន្និដ្ឋានថា សំណាកជាគ្រឿងញៀនប្រភេទម្សៅឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ដែលមានកំរិតភាពសុទ្ធ ៧៥.៣៩% នៃទម្ងន់សរុប វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

៧.ម្សៅក្រាមពណ៌សថ្លាដែលដកហូតពីជនជាប់ចោទឈ្មោះ [redacted] សុថាត់ មានទម្ងន់សុទ្ធ ២៥,៨៧ ក្រាម មានកម្រិតភាពសុទ្ធដូចគ្នាគឺ ៧៥.៣៩% នៃទម្ងន់សរុប ។ ដូចនេះ ថ្នាំញៀនរបស់ឈ្មោះ [redacted] សុថាត់ មានបរិមាណសុទ្ធ (២៥,៨៧X ៧៥,៣៩)១០០= ១៩,៥០ ក្រាម ដែលចំនួននេះច្រើនជាង ១៥ ក្រាម ជាបទឧក្រិដ្ឋ ។

៨.ជនជាប់ចោទជានីតិជន ដែលមានការយល់ដឹងគ្រប់គ្រាន់ចំពោះសកម្មភាពប្រព្រឹត្តរបស់ខ្លួន ហេតុនេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ។

៩.អំពើរបស់ជនជាប់ចោទ ប្រព្រឹត្តឡើងក្នុងចេតនាទុច្ចរិត ជាមនុស្សមានស្មារតីល្អ និងមានការយល់ដឹងច្បាស់លាស់ពីអំពើ និងបច្ច័យដែលកើតមានឡើងនៃអំពើរបស់ខ្លួន តែជនជាប់ចោទនៅតែប្រព្រឹត្តបទល្មើសដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងសុខភាពមនុស្សគួរឱ្យព្រួយបារម្ភ ពិសេសខុសនឹងច្បាប់រដ្ឋជាធរមាន ។

១០.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុថាត់ ដែលមានចេតនាទុច្ចរិតជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើនេះកំណត់បានជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីត្រួតពិនិត្យគ្រឿងញៀន ។

១១.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុថាត់ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិពេជ្ជរ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១២.វត្ថុចាប់យកដូចមានក្នុងដីកាបង្គាប់ឱ្យតម្កល់វត្ថុតាងលេខ ៤៣ វត.ព្រទ/២២ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២ និងកំណត់ហេតុបើកបិទវត្ថុតាង ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរមាន៖



Scanned with CamScanner

ក.ស្រោមសំបុត្រពណ៌សបិទជិត មានស្នាមមេដៃឈ្មោះ [redacted] សុថាត់ និងសមាសភាពចូលរួមចុះហត្ថលេខាចំនួន ០១ ។

ខ-ទូរស័ព្ទដៃម៉ាក VIVO (DUAL CAMERA 1:2.2-2.4 ASPH) មិនស្គាល់Model ពណ៌ស្វាយខ្ចីចំនួន ០១ គ្រឿង ។

គ-ម៉ូតូម៉ាក HONDA DREAM ស៊េរីឆ្នាំ២០២១ តំឡើងតែម២០២២ ពណ៌ខ្មៅ អត់ស្លាកលេខ លេខតួ-លេខម៉ាស៊ីន ៥៩៧៦៧៥៤ (អត់កន្រ្តក អត់កញ្ចក់សងខាង កាំបន្ទះពណ៌ស មានសោរ) ចំនួន ០១ គ្រឿង ។

ឃ-ឡេ Body Lotion (TD) ចំនួន ០១ កំប៉ុង ។

ឃើញថា ជាគ្រឿងញៀន និងជាសម្ភារៈពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសគ្រឿងញៀន ដូចនេះតុលាការ គប្បីសម្រេចរឹបអូសមាត្រា ៩៣ មាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ ។

## ហេតុដូច្នេះ សម្រេច

**១.ផ្តន្ទាទោស៖** ឈ្មោះ [redacted] សុថាត់ ភេទប្រុស អាយុ ២០ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២) ជនជាតិខ្មែរ (ដែលមានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ ០៦ (ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន ១០ (ដប់) លានរៀល ។

ពីបទៈ " ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " ប្រព្រឹត្តនៅភូមិពេជ្ជោរ ឃុំក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ កថាខណ្ឌទី៥ ចំណុចទី៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២.**រឹបអូសវត្ថុចាប់យកតាមមាត្រា៩៣ និងមាត្រា៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មាន៖

ក.ស្រោមសំបុត្រពណ៌សបិទជិត មានស្នាមមេដៃឈ្មោះ [redacted] សុថាត់ និងសមាសភាពចូលរួមចុះហត្ថលេខាចំនួន ០១ ។

ខ.ទូរស័ព្ទដៃម៉ាក VIVO (DUAL CAMERA 1:2.2.4 ASPH) មិនស្គាល់ MODEL ពណ៌ស្វាយខ្ចី ចំនួន ០១ គ្រឿង ។

គ.ម៉ូតូម៉ាក HONDA DREAM ស៊េរីឆ្នាំ២០២១ តំឡើងតែម ២០២២ ពណ៌ខ្មៅ អត់ស្លាកលេខ លេខតួលេខម៉ាស៊ីន ND១២៥ MDM-៥៩៧៦៧៥៤ (អត់កន្រ្តក អត់កញ្ចក់សងខាង កាំបន្ទះ ពណ៌ស មានសោរ) ចំនួន ០១ គ្រឿង ។

ឃ.ឡេ Body lotion (DT) ចំនួន ០១ កំប៉ុង ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ វេលា ព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុថាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ វេលា ព្រឹក ។

**បើកសិទ្ធិឧទ្ធរណ៍តាមកំណត់ច្បាប់ ។**

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា** | **ហត្ថលេខា** | **ហត្ថលេខា និងត្រា** |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
សៀមរាប ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]